ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១ អនក្រ.បក

ក្រសួងមុខងារសាធារណៈ

# អនុក្រឹត្យ

## ស្តីពីការកំណត់រយៈពេលបំរើការងារប្រចាំសប្តាហ៍ របស់មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤_៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណូមពរការងារចាំបាច់

ស សាម៉ុឡឺ

## សំរេច

**មាត្រា ១ :** មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារចំនួន ៥ ថ្ងៃ ក្នុងមួយសប្តាហ៍ និងត្រូវបានអនុញ្ញាតអោយឈប់សំរាកការងារចំនួន ២ ថ្ងៃ ក្នុងមួយសប្តាហ៍ គឺថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ ។

**មាត្រា ២ :** មន្ត្រី រាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញការងារអោយបានទៀងទាត់ តាមរយៈពេលដែលមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះនិងធ្វើការក្នុងមួយថ្ងៃចំនួន ៨ ម៉ោងគឺ ÷

- ព្រឹកពីម៉ោង ៧ និង ០០នាទី ដល់ម៉ោង ១១ និង ៣០នាទី
- ល្ងាចពីម៉ោង ១៤ និង ០០នាទី ដល់ម៉ោង ១៧ និង ៣០នាទី ។

**មាត្រា ៣ :** រយៈពេលបំរើការងារប្រចាំសប្តាហ៍របស់សាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីសិក្សានៃគ្រឹះស្ថានសិក្សានានា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

មាត្រា ៤ : ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រី រាជការស៊ីវិលប្រចាំឆ្នាំ ត្រូវកំណត់ដោយអនុក្រឹត្យ សារាចរ និងលិខិតបទដ្ឋានផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ។

មាត្រា ៥ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល និង អភិបាលគ្រប់ខេត្ត–ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

កន្លែងទទួល :

–ខុទ្ទកាល័យព្រះមហាក្សត្រ
–អគ្គនាយកដ្ឋានព្រះបរមរាជវាំង
–អគ្គលេខាធិការដ្ឋានរដ្ឋសភា
–ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
–ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
–ដូចមាត្រា ៦
–កាលប្បវត្តិ–ឯកសារ